# ស្ថាប័នសម្របសម្រួលពាក្យបណ្តឹងទាមទារសំណងសម្រាប់តំបន់ឆ្នេរឈូងសមុទ្រ

## កំណែទម្រង់ទៅលើវិធានគ្រប់គ្រងជម្រើសទូទាត់សំណងចុងក្រោយ សិទ្ធិអាចទទួលយកបាននិងលក្ខខណ្ឌជាក់ស្តែង និងវិធីសាស្ត្រនៃការទូទាត់ចុងក្រោយ (ចុះថ្ងៃទី 18 ខែកុម្ភៈ ឆ្នាំ 2011)

ថ្ងៃទី 16 ខែសីហា ឆ្នាំ2011

ស្ថាប័នGCCF ជឿជាក់ថាទោះបីជាសេដ្ឋកិច្ចបន្តរីកចំរើន អាជីវកម្មមួយចំនួននឹងរីកចំរើនឡើងវិញយឺតៗជាងវិស័យដទៃទៀត។ កំណែទម្រង់ខាងក្រោមទៅលើវិធានគ្រប់គ្រងជម្រើសទូទាត់សំណងចុងក្រោយ សិទ្ធិអាចទទួលយកបាននិងលក្ខខណ្ឌជាក់ស្តែង និងវិធីសាស្ត្រនៃការទូទាត់ចុងក្រោយរបស់GCCF (ចុះថ្ងៃទី18 ខែកុម្ភៈ ឆ្នាំ 2011) («វិធានចុងក្រោយ») ត្រូវបានបង្កើតឡើងដើម្បីផ្តល់វិធីសាស្ត្រមួយដើម្បីទទួលបានវិធីសាស្ត្រមួយដែលយុត្តិធម៌ និងស៊ីសង្វាក់គ្នាដើម្បីកំណត់និងគណនាការទូទាត់សំណងបណ្តោះអាសន្ននិងចុងក្រោយសម្រាប់បុគ្គលនិងអាជីវកម្មទទួលការខាតបង់នៅឆ្នាំ2011ដោយសារតែការកំពប់ប្រេង។ គោលការណ៍ចុងក្រោយរបស់ស្ថាប័ន GCCF ត្រូវបានគេកែប្រែដូចខាងក្រោម៖

### I. *ការផ្តល់ការទូទាត់សំណងចុងក្រោយ*

ស្ថាប័ន GCCF ទទួលស្គាល់ថាការត្រលប់មករកភាពដើមវិញនៅក្នុងតំបន់ឈូងសមុទ្រកំពុងតែកើតឡើង។ ទោះបីជាយ៉ាងណា ស្ថាប័ន GCCF ជឿថាអនាគតរបស់តំបន់ឈូងសមុទ្រនៅរក្សាភាពមិនទាន់ច្បាស់លាស់នៅឡើយ ដើម្បីធានានូវនិរន្តរភាពនៃកត្តានៃការត្រលប់មករកភាពដើមវិញនាពេលអនាគត សម្រាប់ការខូចខាតឆ្នាំ2010ដែលបានកត់ត្រាទុកពិតប្រាកដដូចដែលបានកំណត់នៅក្នុងវិធានចុងក្រោយរបស់ GCCF។

- ការផ្តល់ការទូទាត់សំណងចុងក្រោយនឹងបន្តគណនាទៅតាមវិធានដែលបានកំណត់ពីមុន នៅក្នុងវិធានចុងក្រោយរបស់ GCCF មានដូចខាងក្រោម(លើកលែងតែបានបញ្ជាក់ខាងក្រោមសម្រាប់អ្នកប្តឹងទាមទារជាមួយនឹងការខាតបង់នៅឆ្នាំ2011 ដែលមិនមានឯកសារសម្រាប់ការខាតបង់ឆ្នាំ2010 និងនៅក្នុងផ្នែកIV។ ការកែប្រែសម្រាប់អ្នកជួលអាជីវកម្មគ្រំសមុទ្រ៖

> ចំនួនទឹកប្រាក់ផ្តល់សម្រាប់ការទូទាត់សំណងចុងក្រោយរបស់អ្នកទាមទារម្នាក់ៗនឹងធំជាង៖
>
> 1) ពីរដងនៃការខាតបង់របស់អ្នកប្តឹងទាមទារឆ្នាំ2010 ដែលបានកត់ត្រាពិតប្រាកដ (លើកលែងតែអ្នកប្តឹងទាមទារការខាតបង់ឆ្នាំ2010ដែលលើសពី $500,000) បួនដងនៃការខាតបង់ដែលបានកត់ត្រាពិតប្រាកដឆ្នាំ2010 សម្រាប់អ្នកនេសាទគ្រំសមុទ្រ និងអ្នកចំរាញ់យកផលគ្រំសមុទ្រនិងសម្រាប់**អ្នកជួលអាជីវកម្មគ្រំសមុទ្រប៉ុណ្ណោះ** បន្ថែមពីលើមេគុណហានិភ័យនាពេលអនាគតដូចដែលបានបញ្ជាក់ខាងក្រោមនៅក្នុងផ្នែកIV។ ការកែប្រែសម្រាប់អ្នកជួលអាជីវកម្មគ្រំសមុទ្រ ឬ
> 2) ការខាតបង់ដែលបានកត់ត្រាទុកពិតប្រាកដសរុបតាមរយៈកាលបរិច្ឆេទនៃការកំណត់ដាក់ពាក្យប្តឹងទាមទារសំណងចុងក្រោយ។

- ការផ្តល់ការទូទាត់សំណងចុងក្រោយសម្រាប់អ្នកប្តឹងទាមទារ**ដែលគ្មានឯកសារសំអាងពីការបាត់បង់នៅឆ្នាំ2010** នឹងត្រូវបានគេពិនិត្យនិងគណនាដោយប្រើប្រាស់ការខាតបង់នៅឆ្នាំ2011ដែលសន្មតថាកើតឡើង ដោយសារការកំពប់ប្រេង។ ការប្តឹងទាមទារទាំងនេះត្រូវតែផ្តល់ភស្តុតាងជាពិសេសដោយភ្ជាប់ជាមួយនឹងការទាមទារចំពោះការបាត់បង់ដោយសារការលេចប្រេង។ ការផ្តល់ការបង់ប្រាក់ចុងក្រោយសម្រាប់ការប្តឹងទាមទារទាំងអស់នឹងត្រូវបានគេគណនាតាមករណីនីមួយៗជាក់ស្តែង។

  ភាពមិនផ្លាស់ប្តូរជាមួយនឹងគោលការណ៍ចុងក្រោយ,[1] (សម្រាប់អ្នកទាមទារសំណងទាំងអស់ ការផ្តល់សំណងនឹងត្រូវបានកាត់បន្ថយតាមរយៈសំណងថ្លៃខូចខាតដែលបានទទួលរួចរាល់ក្នុងការសងសំណងបន្ទាន់ពីក្រុមហ៊ុន BP ការសងសំណងបន្ទាន់ និងការសងសំណងបណ្តោះអាសន្នដែលទទួលបានពី GCCF និងការទូទាត់សងផ្សេងៗទៀត)។

## *II. ការទាមទារការបង់ប្រាក់ស្តីទី*

- ការទាមទារស្តីទីសម្រាប់អាជីវកម្មៈ

  សម្រាប់ការទាមទារស្តីទីដែលបានដាក់ដោយអាជីវកម្មសម្រាប់ឆមាសទីពីរនៃការបាត់បង់នៅឆ្នាំ2011 (និងបន្ទាប់ពីនោះ) ស្ថាប័នGCCF នឹងតម្រូវថាអាជីវកម្មទាំងអស់បង្ហាញអត្រារីកចំរើនជាក់ស្តែងយ៉ាងហោចណាស់5% ពីឆ្នាំ2010។ ការបាត់បង់ទាំងឡាយណាដែលជាប់ទាក់ទងនឹងចំណូលដែលតិចជាងអត្រារីកចំរើន 5%គឺត្រូវបានគេគិតថាកើតពីកត្រាដែលមិនទាក់ទងនឹងកត្តាការកំពប់ប្រេងនិងមិនត្រូវបានគេទូទាត់ឡើយ។ (សម្រាប់ព័ត៌មានលំអិតស្តីពីវិធីសាស្ត្រសម្រាប់ការគណនានៃការបាត់បង់នៅឆ្នាំ2011។ សូមមើលឯកសារភ្ជាប់Aៈ «ARPC វិធីសាស្ត្រសម្រាប់ការគណនាការបង់ប្រាក់ស្តីទីសម្រាប់ការបាត់បង់នៅឆ្នាំ2011 ការបាត់បង់ដោយសារតែការកំពប់ប្រេង» រៀបរៀងដោយ ARPC និងក្រុមហ៊ុនជំនាញនៃសេដ្ឋវិទូដែលផ្តល់សេវាដោយ GCCF។

- ការប្តឹងទាមទារស្តីទីសម្រាប់បុគ្គលៈ

  - GCCF នឹងតម្រូវឱ្យបុគ្គលដែលមានការងារធ្វើទាំងអស់បង្ហាញនូវកំណើនជាក់ស្តែងនៅក្នុងកម្រៃនៃអត្រាយ៉ាងតិច 5%ពីចំណូលឆ្នាំ2010។ តែទោះជាយ៉ាងណា,សម្រាប់ការប្តឹងទាមទារជាបុគ្គល,ការកែប្រែនេះនឹងមិនមានផលប៉ះពាល់រហូតដល់ការដាក់ពាក្យទាមទារស្តីទីនៅឆមាសទីបីនៃឆ្នាំ2011 (និងបន្ទាប់ពីនោះ) សម្រាប់ការបាត់បង់កើតពីដើមថ្ងៃទី1 ខែកក្កដា ឆ្នាំ2011។ ( ការបាត់បង់សម្រាប់អ្នកទាមទារជាបុគ្គលដែលបានដាក់ពាក្យប្តឹងទាមទារសម្រាប់ឆមាសទីមួយនិងទីពីរនៃឆ្នាំ2011នឹងត្រូវបានគេទូទាត់ឱ្យតាមវិធីសាស្ត្រគណនាជាក់ស្តែងរបស់ GCCF ដូចដែលបានកំណត់នៅក្នុងគោលការណ៍ចុងក្រោយរបស់ GCCF។ ការបាត់បង់ទាំងឡាយដែលជាប់ទាក់ទងនឹងអត្រានៃកំនើននៃការរកចំណូលដែលតិចជាង5% ត្រូវបានគេចាត់ទុកថាមកពីកត្តាផ្សេងទៀតក្រៅពីការកំពប់ប្រេងនិងមិនត្រូវបានគេបង់ការខូចខាតឱ្យឡើយ។

  - ចំពោះបុគ្គលដែលអះអាងថាបានបាត់បង់ការដោយសារតែការកំពប់ប្រេង GCCF នឹងអនុញ្ញាតិឱ្យបុគ្គលដែលមានសិទ្ធិទទួលបានបន្តទទួលបានការបង់ប្រាក់ឱ្យតាមរយៈដំណើរការបង់ប្រាក់ស្តីទីរបស់ GCCF សម្រាប់រយៈពេលអតិបរមា78 សប្តាហ៍នៃការបង់ឱ្យថ្លៃគ្មានការងារធ្វើបណ្តាលមកពីការកំពប់ប្រេងដោយ

---

[1]សូមមើលគោលការណ៍ចុងក្រោយពីទំព័រ5-6 *ការគណនានៃរង្វាន់សម្រាប់ការបង់ប្រាក់ស្តីទីនិងចុងក្រោយ*
http://www.gulfcoastclaimsfacility.com/FINAL_RULES.pdf.

មានឯកសារគាំទ្រដែលបានផ្តល់ឱ្យដោយអ្នកទាមទារ។ GCCF នឹងពិនិត្យការបន្តទាមទារទាំងអស់ ហើយនឹងកំណត់ឯកសារតម្រូវបន្ថែមសម្រាប់បុគ្គលដែលបានទាមទារលើសពីរយៈពេលគ្មានការងារធ្វើ 78សប្តាហ៍។

- ការទាមទារសម្រាប់អាជីវកម្មនិងបុគ្គលទាំងអស់ដែលមិនត្រូវបានរកឃើញដោយ GCCF ដើម្បីទទួលការបង់ប្រាក់សម្រាប់ការខូចខាត៖ អ្នកទាមទារទាំងនេះត្រូវតែបង្ហាញគុណសម្បត្តិសិទ្ធិទទួលបានសម្រាប់ការបង់ប្រាក់ដូចដែលបានកំណត់នៅក្នុងផ្នែក IV.3. (a) (b) និង (c) នៃគោលការណ៍ចុងក្រោយរបស់ GCCF។ ប្រសិនបើគ្មានការខាតបង់ទាំងឡាយនៅឆ្នាំ2010ត្រូវបានបង្ហាញអ្នកទាមទារទាំងអស់ត្រូវផ្តល់ភស្តុតាងជាពិសេសទាក់ទងនឹងការខាតបង់នៅឆ្នាំ2011 ដែលអះអាងថាកើតឡើងដោយសារការកំពប់ប្រេងដើម្បីមានសិទ្ធិទទួលបានសំណងពី GCCF។

## *III. កំណែតេស្តហិរញ្ញវត្ថុ (ឯកសារភ្ជាប់ C ទៅនឹងវិធានចុងក្រោយរបស់GCCF)*

តេស្តផ្នែកហិរញ្ញវត្ថុបានពន្យល់នៅក្នុងឯកសារភ្ជាប់ C ទៅនឹង «វិធានចុងក្រោយ» របស់ GCCF ថាជាការវិភាគពីសិទ្ធិត្រូវទទួលបានដើម្បីកំណត់ថាតើការខូចខាតដោយសារការកំពប់ប្រេងគួរត្រូវបានគេសន្មតដែរឬទេ។ តេស្តផ្នែកហិរញ្ញវត្ថុត្រូវបានប្រើប្រាស់ដើម្បីបង្ហាញថាតើការធ្លាក់ចុះនៃចំណូលនៅក្នុងពេលមុនការកំពប់ប្រេងទាក់ទងនឹងចំណូលនៅក្នុងពេលវេលាដូចគ្នានៅក្នុងឆ្នាំមុនៗ កើតឡើងដោយសារការកំពប់ប្រេង ឬកត្តាផ្សេងៗទៀត។ ដើម្បី «ជាប់» តេស្តផ្នែកហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន ត្រូវតែមានការខូចខាតខ្លះពីបួនខែដំបូងនៃឆ្នាំ2010 (មុនពេលកំពប់ប្រេង) ដោយប្រៀបធៀបនឹងប្រាំបីខែចុងក្រោយនៃឆ្នាំ2010 (ក្រោយកំពប់ប្រេង)។

ក្នុងករណីជាច្រើន ភាពប្រែប្រួលខ្ពស់នៃប្រវត្តិចំណូលមិនស៊ីគ្នានឹងបទដ្ឋានសម្រាប់តេស្តដែលត្រូវបាន បង្កើតឡើងដំបូង។ អាជីវកម្មដែលប្តឹងទាមទារខ្លះខ្វះទិន្នន័យប្រវត្តិហិរញ្ញវត្ថុដែលត្រូវការដើម្បីធ្វើតេស្តនិន្នាការផ្នែកហិរញ្ញវត្ថុ។ នៅក្នុងករណីជាក់ស្តែងនៃស្ថានភាពតេស្តហិរញ្ញវត្ថុទាំងនេះដូចដែលបានបង្ហាញនៅក្នុងវិធានចុងក្រោយរបស់ GCCFអាចមិនគ្រប់គ្រាន់ដើម្បីកំណត់ពីសិទ្ធិទទួលបានផ្នែកហិរញ្ញវត្ថុ។ ការទាមទារបែបនេះនឹងត្រូវបានគេពិនិត្យនិងគិតគូរដោយយកចិត្តទុកដាក់យោងទៅតាមស្ថានភាពជាក់ស្តែងនៃប្រវត្តិហិរញ្ញវត្ថុរបស់អ្នកប្តឹងទាមទារដើម្បីកំណត់ថា តើទិន្នន័យហិរញ្ញវត្ថុដែលបានផ្តល់ឱ្យដោយអ្នកប្តឹងទាមទារបង្ហាញពីផលប៉ះពាល់ដែលអាចកើតមានដោយសារការកំពប់ប្រេងឬទេ។

## *IV. កំណែសម្រាប់អ្នកជួលអាជីវកម្មគ្រំសមុទ្រ*

កំណែនេះត្រូវបានបង្កើតឡើងដោយផ្តល់នូវវិធីសាស្ត្រសម្រាប់វិធីដែលមានយុត្តិធម៌និងសមធម៌ដើម្បីសងថ្លៃខូចខាតឱ្យអ្នកជួលអាជីវកម្មគ្រំសមុទ្រនៅក្នុងតំបន់ឈូងសមុទ្រMexicoដែលត្រូវខូចខាតផ្នែកហិរញ្ញវត្ថុដោយការបិទកន្លែងចិញ្ចឹមគ្រំសមុទ្រ ការបង្វែរទឹកសាប,និង/ឬការបំពុលដោយសារការកំពប់ប្រេង។ កំណែនេះទទួលស្គាល់ថាមានភាពមិនប្រាកដច្រើនទាក់ទងនឹងការខូចខាតជាបន្តបន្ទាប់ចំពោះតំបន់គ្រំសមុទ្រនិងផលិតកម្មគ្រំសមុទ្រនៅក្នុងតំបន់ឈូងសមុទ្រ។ ការកែប្រែនេះទទួលស្គាល់ការខាតបង់ដែលអាចកើតមានបីយ៉ាងខុសគ្នាចំពោះអ្នកជួលអាជីវកម្មគ្រំសមុទ្រដូចខាងក្រោម៖

- ការខាតបង់នៃចំណូល/កម្រៃនៅពេលកំពប់ប្រេងនៅក្នុងឆ្នាំ2010 ដោយសារតែ៖

- o ការបិទរបស់រដ្ឋ/សហព័ន្ធ ឬ
- o ការកាត់បន្ថយសន្និធិពីការហូរចូលទឹកសាបទាក់ទងនឹងសកម្មភាពរបស់រដ្ឋាភិបាលដើម្បីបង្វែរការកំពប់ប្រេងដែលអាចធ្វើឱ្យកើនឡើងនៃអត្រាមរណៈនៅក្នុងឆ្នាំនោះ។[2]

- ការខូចខាតដែលអាចកើតមានជាបន្តបន្ទាប់នៅក្នុងពេលនៃការត្រលប់ទៅរកភាពដើមវិញនៃដំនើរវដ្តផលិតកម្មរបស់គ្រំសមុទ្រ[3] និង/ឬ
- ហានិភ័យដែលមានសម្រាប់ការខូចខាតទាក់ទងនឹងការកំពប់ប្រេងរយៈពេលយូរចំពោះកន្លែងចិញ្ចឹមគ្រំសមុទ្រ និងសមត្ថភាពរបស់ពួកគេដើម្បីគាំទ្រវដ្តបន្តពូជជំនាន់ក្រោយរបស់គ្រំសមុទ្រ។

ក្រោមនីតិវិធីនាពេលបច្ចុប្បន្ន ការគណនាទូទាត់សំណងចុងក្រោយចាប់ផ្តើមជាមួយនឹងការកំណត់ការខាតបង់នៅឆ្នាំ 2010សម្រាប់អ្នកនេសាទទាំងអស់។ វិធីសាស្ត្រគណនារបស់GCCF នាពេលបច្ចុប្បន្នសម្រាប់ការកំណត់ការផ្តល់ប្រាក់ទូទាត់ចុងក្រោយសម្រាប់អ្នកប្តឹងទាមទារទាំងឡាយដែលពាក់ព័ន្ធដោយផ្ទាល់នៅក្នុងឧស្សាហកម្មគ្រំសមុទ្រ ឧ. អ្នកជួល អ្នកនេសាទ (ថៅហ្វាយនិងកូនថៅ) និងអ្នកចំរាញ់គឺបួនដងនៃកម្រៃខាតបង់ឆ្នាំ2010។ សំណងរបស់ពួកគេបន្តត្រូវបានកំណត់ដោយលក្ខណៈដូចគ្នាដូចដែលបានពិពណ៌នានៅក្នុងវិធានចុងក្រោយរបស់GCCF។ កំណែដែលបានពិភាក្សាខាងក្រោមនឹងត្រូវបានអនុវត្តចំពោះ<u>អ្នកជួលអាជីវកម្មគ្រំសមុទ្រប៉ុណ្ណោះ</u>ដូចដែលថែងខាងក្រោម។

វិធីសាស្ត្រដែលបានកែប្រែនេះបន្តសងសម្រាប់ការខូចខាតឆ្នាំ2010 និងការខាតបង់បន្ត បន្ទាប់ទៀតនៅក្នុង អំឡុងពេលរំពឹងគិតចំពោះការត្រឡប់មករកភាពដើមវិញ<u>ក្នុងលក្ខណៈដូចគ្នា</u>។ ទោះជាយ៉ាងណា សម្រាប់<u>អ្នកជួល អាជីវកម្មគ្រំសមុទ្រប៉ុណ្ណោះ</u>ការផ្តល់ប្រាក់ទូទាត់ចុងក្រោយ លើសពីនេះទៅទៀត នឹងរាប់បញ្ចូលប្រាក់ពិសេស សម្រាប់ ហានិភ័យនាពេលអនាគតដែលនឹងត្រូវបន្ថែមដើម្បីទូទាត់សងហានិភ័យដែលមិនទាន់បានរកឃើញនិងការខូចខាត បន្តបន្ទាប់ចំពោះតំបន់ផលិតកម្មគ្រំសមុទ្រនៅក្នុងតំបន់ឈូងសមុទ្រនិងលទ្ធភាពនៃការពន្យាដ៏សំខាន់មុនកន្លែង ចិញ្ចឹមគ្រំសមុទ្រត្រូវបានគេជួសជុល។ សម្រាប់អ្នកជួលអាជីវកម្មនៅ Louisiana, Mississippi, Alabama និងតំបន់ខ្លះនៃ Florida Panhandle ប្រាក់ឧបត្ថម្ភសម្រាប់ហានិភ័យនាពេលអនាគតនឹងកើនឡើង («មេគុណហានិភ័យនាពេលអនាគត») នៃចំណូលសុទ្ធនៅក្នុងឆ្នាំប្រៀបធៀប («ចំណូលប្រចាំឆ្នាំសុទ្ធប្រៀបធៀប») បន្ថែមលើការផ្តល់ប្រាក់ទូទាត់ចុងក្រោយ សម្រាប់អ្នកទាមទារ។ **មេគុណហានិភ័យនាពេលអនាគតនឹងអនុវត្តចំពោះអ្នកជួលអាជីវកម្មរបស់ជំនួញនេះប៉ុណ្ណោះ។ ដើម្បីបាន**

---

[2]ការចូលទឹកសាបដែលកើតមានឡើងនៅរដ្ឋ Mississippi នៅពេលកំពប់ប្រេងនិងទឹកជន់នៅតំបន់ដីសន្តខាងក្រោម។ Dr. Earl Melancon ពី Nicholls State Universityបានបង្ហាញថាសកម្មភាពនេះរួមនឹងសកម្មភាពដោះស្រាយដទៃរបស់រដ្ឋLouisiana បានធ្វើឱ្យ «ខូច»កន្លែងចិញ្ចឹមគ្រំសមុទ្រទាំងអស់។

សូមមើល[3] *«ចម្លើយរបស់ARPC ចំពោះយោបល់ស្តីពីប្រភពនិងការគណនាការខូចខាតនាពេលអនាគត»* លើគេហទំព័រ GCCF– http://www.gulfcoastclaimsfacility.com/FINAL_RULES_B.pdf។

**សិទ្ធិទទួលបានមេគុណហានិភ័យនាពេលអនាគតអ្នកជួលអាជីវកម្មត្រីសមុទ្រនឹងត្រូវបានគេស្នើឱ្យបំពេញពាក្យទាមទារការខូចខាតទ្រព្យសម្បត្តិពីGCCF បន្ថែមលើការទាមទារប្រាក់ចំណូល/ការចំនេញដែលខាតបង់របស់ពួកគេ។** ការប្រៀបធៀបប្រាក់ចំណូលសុទ្ធប្រចាំឆ្នាំជាទូទៅគឺអាស្រ័យលើតំលៃជាមធ្យមនៃឆ្នាំ2008-2009 ឬចំណូលរបស់អ្នកទាមទារនៅឆ្នាំ2009 ប្រសិនបើវាខ្ពស់ជាង។[4] អាជីវកម្មដែលទាក់ទងផ្ទាល់ក្នុងឧស្សាហាកម្មត្រីសមុទ្រ ឧ. អ្នកនេសាទ (ថៅហ្វាយនិងកូនថៅ) និងអាជីវកម្មផលិតកម្មនិងចំរាញ់មិនត្រូវទទួលបានសិទ្ធិទទួលបានប្រាក់សម្រាប់ហានិភ័យនាពេលអនាគតឡើយ។ <u>មានតែអ្នកជួលអាជីវកម្មប៉ុណ្ណោះ</u>ដែលមានសិទ្ធិទទួលបានប្រាក់សម្រាប់ហានិភ័យនាពេលអនាគតនេះ។

### មេគុណហានិភ័យនាពេលអនាគត

GCCF បានកំណត់ប្រភេទនៃការខូចខាតបីផ្សេងគ្នានិងបានកំណត់មេគុណហានិភ័យនាពេលអនាគតចំពោះករណីនីមួយៗដោយអាស្រ័យលើកន្លែងចិញ្ចឹមត្រីសមុទ្រ។ ប្រាក់សម្រាប់ហានិភ័យនាអនាគតគឺស្មើនឹងផលិតផលនៃចំណូលប្រចាំឆ្នាំសុទ្ធប្រៀបធៀបនិងមេគុណហានិភ័យនាពេលអនាគតផ្អែកលើទីតាំងភូមិសាស្ត្រនៃកន្លែងចិញ្ចឹមត្រីសមុទ្រ។

- ផ្អែកលើការពិនិត្យនៃតំបន់ដែលជួលនៅក្នុងតំបន់នេសាទ («ចតុកោណ») នៅក្នុងរដ្ឋ Louisiana (ផែនទី1)[5]ទិន្នន័យស្តីពីការបង្វែរទឹកសាប(ផែនទី2)[6] និងការជ្រាបចូលរបស់ប្រេង(ផែនទី3)[7]GCCF បានកំណត់ ការខូចខាតបីប្រភេទផ្សេងគ្នា និងកំណត់ពីមេគុណហានិភ័យនាពេលអនាគតចំពោះប្រភេទនីមួយៗ (សូមមើលឯកសារភ្ជាប់Bសម្រាប់ផែនទី1-4។)

---

[4] ប្រសិនបើអ្នកនេសាទត្រីសមុទ្របង្ហាញថាការនេសាទរបស់ពួកគាត់ពីអតីតកាលនៅក្នុងអំឡុងពេលនេះគឺខុសពីពេល«ធម្មតា» GCCF នឹងពិចារណាភស្តុតាងសមរម្យនៃពេលវេលាសមរម្យជាងនេះ។

[5] Louisiana Department of Wildlife and Fisheries- ផ្អែកស្ទង់មតិជួលត្រីសមុទ្រ។

[6] Louisiana Department of Wildlife and Fisheries, ខែមីនាឆ្នាំ2005។ អត្រាលំហូរដកស្រង់ពី Office of Coastal Protection and Restoration, LA; http://coastal.louisiana.gov/index.cfm?md=newsroom&tmp=detail&articleID=1216&catID=1។

[7] «តំបន់ទឹកជ្រៅ មួយឆ្នាំក្រោយមក» អ្នកសេដ្ឋកិច្ច៖ http://www.economist.com/node/18587367។

ទិន្នន័យពីផែនទី 3 ប្រភពបានមកពី Office of Response and Restoration - Deepwater Horizon Trajectory Map Archive Near shore Surface Oil Forecasts. http://response.restoration.noaa.gov/topic_subtopic_entry.php?RECORD_KEY%28entry_subtopic_topic%29=entry_id,subtopic_id,topic_id&entry_id(entry_subtopic_topic)=831&subtopic_id(entry_subtopic_topic)=2&topic_id(entry_subtopic_topic)=1។

ខ្ពស់៖ (មេគុណ= ចំនួនប្រាំពីរដងនៃចំណូលប្រចាំឆ្នាំសុទ្ធប្រៀបធៀប)

មធ្យម៖ (មេគុណ= ចំនួន3.5 ដងនៃចំណូលប្រចាំឆ្នាំសុទ្ធប្រៀបធៀប)

ទាប៖ (មេគុណ= ចំនួនពីរដងនៃចំណូលប្រចាំឆ្នាំសុទ្ធប្រៀបធៀប)

(មេគុណ= ចំនួនមួយដងនៃចំណូលប្រចាំឆ្នាំ សុទ្ធប្រៀបធៀប សម្រាប់រដ្ឋ **Florida (ជួលនៅApalachicola Bay & points west ប៉ុណ្ណោះ)**

ពិន្ទុទាំងនេះគឺជាមេគុណហានិភ័យនាពេលអនាគតដែល

- អ្នកជួលនៅ **Louisiana** នឹងត្រូវបានគេកំណត់ពីមេគុណហានិភ័យនាពេលអនាគតសម្រាប់តំបន់ជួលនីមួយៗ ដែលគេហៅថា «ចតុកោណ» ដោយLouisiana Department of Wildlife and Fisheries។[8] មេគុណនឹងត្រូវធ្វើ ផ្អែកលើ Quad ដែលមានអត្រាខ្ពស់ជាងគេបំផុតសម្រាប់ការជួលជាក់ស្តែង។ ផែនទី 4[9] បង្ហាញពីព្រំដែនចតុកោណ និងមេគុណហានិភ័យនាពេលអនាគតរបស់ពួកគេ។ (អ្នកជួលអាជីវកម្មគ្រំសមុទ្រដែលផ្ទៃដីមិនមានសកម្មភាពផលិតកម្មរយៈពេលប្រាំឆ្នាំនឹងមិនត្រូវទទួលបានការបង់ការខូចខាតសម្រាប់ការខាតបង់នាពេលអនាគតឡើយ ។) មេគុណហានិភ័យនាពេលអនាគតអតិបរិមាសម្រាប់ការខូចខាតដោយទឹកសាបនិងប្រេងចំពោះការជួលនៅក្នុងរដ្ឋ Louisianaគឺគុណប្រាំពីរដងនៃចំណូលប្រចាំឆ្នាំសុទ្ធប្រៀបធៀប។ កម្រិតអប្បបរមាគឺមេគុណពីរនៃចំណូលប្រចាំឆ្នាំសុទ្ធប្រៀបធៀបសម្រាប់ចតុកោណ ដែលមានតែការបំពុលប្រេងមួយចំនួនតូច ប៉ុណ្ណោះត្រូវបានកត់សម្គាល់។

- អ្នកជួលនៅក្នុងរដ្ឋ **Mississippi** និង**Alabama** នឹងត្រូវបានគេផ្តល់ឱ្យមេគុណហានិភ័យនាពេលអនាគតចំនួន3.5 ដងនៃចំណូលប្រចាំឆ្នាំសុទ្ធប្រៀបធៀប។ ចំនុចនេះឆ្លុះបញ្ចាំងភាពជាក់ស្តែងដែលថាឆ្នេរសមុទ្ររដ្ឋ Mississippi និងរដ្ឋ Alabama បានទទួលរងនូវការបំពុលដោយប្រេងក្នុងកម្រិតគួរកត់សម្គាល់មួយប្រហាក់ប្រហែលនឹងការបំពុលនៅតាមឆ្នេរសមុទ្ររដ្ឋ Louisiana ផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ការចូលទឹកសាបមិនមានអ្វីធំដុំទេនៅក្នុងរដ្ឋទាំងនេះ។

---

[8] គេហទំព័រសាធារណៈរបស់Louisiana Department of Wildlife and Fisheries បង្ហាញទីតាំងចតុកោណនីមួយៗ ក៏ដូចជាទិន្នន័យដែលជួលដោយអ្នកជួលឯកជន។ ការជួលជាឯកជននីមួយៗត្រូវបានកំណត់ដោយរដ្ឋទៅចតុកោណមួយ។ GCCF នឹងពឹងផ្អែកលើបញ្ជីនេះដើម្បីធ្វើការកំណត់ការជួលសម្រាប់បុគ្គលដាក់ពាក្យប្តឹងទាមទារម្នាក់ៗ http://oysterlease.wlf.la.gov/oysterlease1/framesetup.asp។

[9] Louisiana Department of Wildlife and Fisheries – ផ្អែកស្ទង់មតិជួលគ្រំសមុទ្រសម្រាប់«ចតុកោណ»។

- ការទាមទារខ្លះនៅក្នុងរដ្ឋ **Florida (ចំពោះតែការជួលនៅ Apalachicola Bay និង points west ប៉ុណ្ណោះ)** នឹងត្រូវបានគេកំណត់មេគុណហានិភ័យនាពេលអនាគត 1.0 នៃចំណូលប្រចាំឆ្នាំសុទ្ធប្រៀបធៀប។ ចំនុចនេះឆ្លុះបញ្ចាំងភាពជាក់ស្តែងដែលថាឆ្នេរសមុទ្រទាំងនេះបានជួបប្រទះការបំពុលប្រេង ទោះបីជាវាមានតិចតួចជាងនៅរដ្ឋ Mississippi និងរដ្ឋ Alabama។ ការចូលទឹកសាបមិនមានអ្វីធំដុំទេនៅក្នុងតំបន់ទាំងនេះ។

  **អ្នកជួលអាជីវកម្មគ្រំសមុទ្រនៅរដ្ឋ Florida ភាគខាងកើតនៃ Apalachicola Bay និងការទាមទាររបស់អ្នកជួលអាជីវកម្មគ្រំសមុទ្រនៅរដ្ឋ Texas** មិនមានសិទ្ធិទទួល ធ្វើជាអ្នកជួលធ្វើអាជីវកម្មគ្រំសមុទ្រ នៅភាគខាងកើតរដ្ឋ **Florida** នៃ **Apalachicola Bay** គ្រប់អ្នកជួលធ្វើអាជីវកម្មគ្រុំសមុទ្រនៅរដ្ឋ **Texas** មិនមានសិទ្ធិទទួលបានប្រាក់សម្រាប់ការខូចខាតនាពេលអនាគតនេះឡើយ។ [10] គ្រំសមុទ្រនៅក្នុងតំបន់ទាំងនេះមិនបានទទួលការប៉ះពាល់ដោយការចូលទឹកសាប ឬប្រេងជាធំដុំនោះទេ។

ការកែតម្រូវ (ការឆ្លុះបញ្ចាំងភាគរយនៃការកាត់បន្ថយនៅក្នុងផលិតកម្ម) នឹងត្រូវបានគេអនុវត្តចំពោះមេគុណហានិភ័យនាពេលអនាគតនៅក្នុងព្រឹត្តិការណ៍ដែលអ្នកជួលបានប្រមូលផលគ្រំសមុទ្រនៅឆ្នាំ2011ឬចាប់ពីពេលជួល
ដែលការខាតបង់នាពេលអនាគតត្រូវបានគេទាមទារ។ [11]

---

[10] នៅឆ្នាំ2002 មានអាជីវកម្មជួលគ្រំសមុទ្រចំនួន43 នៅក្នុងរដ្ឋ Texas ពួកវាទាំងអស់នៅ Galveston Bay។ គ្រំសមុទ្រពីកន្លែងអាជីវកម្មជួលមានចំនួនមួយភាគបីនៃគ្រំសមុទ្រនៅទឹកដីរដ្ឋTexas។ មានកន្លែងជួលចិញ្ចឹមគ្រំសមុទ្រតិចតួចនៅរដ្ឋ Florida ហើយពួកវាភាគច្រើនគឺនៅតំបន់ Apalachicola Bay។

[11] សម្រាប់ចតុកោណដែលបានកំណត់អត្រា7 មេគុណហានិភ័យនាពេលអនាគតដែលបានកែតម្រូវនឹងមានជាអប្បរមា 3.5 សម្រាប់ការជួលនៅរដ្ឋ Mississippi និង Alabama ហើយចតុកោណដែលបានកំណត់អត្រា 3.5 មេគុណការខូចខាតនាពេលអនាគតដែលបានកែតម្រូវនឹងមានជាអប្បរមា 1.75 សម្រាប់ចតុកោណ ដែលបានកំណត់អត្រា 2.0 មេគុណការខូចខាតនាពេលអនាគតដែលបានកែតម្រូវនឹងមានជាអប្បរមា 1.0 ហើយសម្រាប់Florida Panhandle ខាងលិចដែលបានកំណត់អត្រា 1.0 មេគុណការខូចខាតនាពេលអនាគតដែលបានកែតម្រូវនឹងមានជាអប្បរមា 0.5។